CDRI
Cambodia Development Resource Institute

សង្ខេបសម្រាប់
គោលនយោបាយ

២០២៤ លេខ ០១

# បង្រួមគម្លាតព័ត៌មាន៖ ដោះស្រាយបញ្ហាតម្រូវការព័ត៌មានសម្រាប់ជនមានពិការភាពនៅកម្ពុជា

## ព័ត៌មានសំខាន់ៗ

- នៅក្នុងប្រទេសកម្ពុជា មនុស្សម្នាក់ក្នុងចំណោមមនុស្ស ៤នាក់ ដែលមានអាយុលើសពី ៥ឆ្នាំ ត្រូវបានគេប៉ាន់ស្មានថា មានពិការភាពផ្នែកណាមួយ។ ជនដែលមានពិការភាពភាគច្រើន ជាមនុស្សចាស់ ស្ត្រី និងជាប្រជាជនរស់នៅតាមតំបន់ជនបទ។ អត្តសញ្ញាណពិការភាព ឬភាពលំបាកភាគច្រើន រួមមាន ភាពលំបាកក្នុងការមើលឃើញ ការចងចាំ និងការដើរ ឬការធ្វើចលនាបម្លាស់ទី ជាដើម។
- ឱកាសនៃការទទួលបានការអប់រំ និងមានការងារធ្វើ នៅមានកម្រិត ជាពិសេសសម្រាប់ស្ត្រីដែលមានពិការភាពធ្ងន់ធ្ងរ។ ជាទូទៅ សុខភាព និងជីវភាពរបស់ពួកគាត់ មានកម្រិតទាបនៅឡើយ។
- ប្រទេសកម្ពុជាមិនទាន់មានក្របខណ្ឌច្បាប់ជាក់លាក់ណាមួយនៅឡើយ ទាក់ទងទៅនឹងការទទួលបានព័ត៌មាន ជាពិសេសសម្រាប់ជនមានពិការភាព ដែលជាហេតុនាំឱ្យមានការលំបាកក្នុងការអនុវត្តច្បាប់។
- ជនមានពិការភាពទទួលបានព័ត៌មាន តាមរយៈមធ្យោបាយចំនួនបួន (ប្រព័ន្ធផ្សព្វផ្សាយសាធារណៈ ភ្នាក់ងារ ព្រឹត្តិការណ៍ និងសម្ភារៈ IEC ឬសម្ភារៈព័ត៌មាន អប់រំ និងទំនាក់ទំនង[១]) ក៏ប៉ុន្តែភាពសមស្របនៃមធ្យោបាយទាំងនេះ អាចមានលក្ខណៈ និងឥទ្ធិពលខុសគ្នា អាស្រ័យទៅលើប្រភេទ និងកម្រិតធ្ងន់ធ្ងរនៃពិការភាពរបស់ជនមានពិការភាព។
- ក្រៅពីព័ត៌មានដែលទទួលបាន និងមធ្យោបាយទទួលព័ត៌មាននាពេលបច្ចុប្បន្ន ជនមានពិការភាពត្រូវការព័ត៌មានបន្ថែមទាក់ទងនឹងសេដ្ឋកិច្ច ការអប់រំ ការថែទាំសុខភាព និងព័ត៌មានជាច្រើនទៀត។ ព័ត៌មានទាំងនោះ គួរតែជាព័ត៌មានជាក់លាក់ បានបកប្រែមានភាពច្បាស់លាស់ ខ្លឹមសារសាមញ្ញ ផ្តល់ជូនទាន់ពេលវេលា និងសម្របតាមប្រភេទពិការភាពផ្សេងៗ។

## សេចក្តីផ្តើម

បុគ្គលគ្រប់រូប រួមទាំងជនមានពិការភាព មានសិទ្ធិទទួលបានព័ត៌មានជាមូលដ្ឋានស្មើៗគ្នា។ ប៉ុន្តែជនមានពិការភាព ជួបប្រទះនឹងឧបសគ្គជាច្រើនដែលបានរារាំងពួកគេ ក្នុងការសម្រេចបានសិទ្ធិទាំងនោះ។ ឧបសគ្គទាំងនោះរួមមាន (១) កង្វះបច្ចេកវិទ្យា និងឧបករណ៍ជំនួយ (២) កង្វះទម្រង់ និងខ្លឹមសារប្រព័ន្ធផ្សព្វផ្សាយសម្រាប់ជនមានពិការភាព និង (៣) ការរើសអើងក្នុងបទដ្ឋានសង្គម និងគោលនយោបាយសាធារណៈ (Madaus et al. 2021; Mitra and Palmer 2023; UN 2006)។

ដូចគ្នានឹងប្រទេសជាច្រើនទៀត ប្រទេសកម្ពុជានៅខ្វះក្របខ័ណ្ឌច្បាប់ទូលំទូលាយដើម្បីធានាថា ជនមានពិការភាពអាចទទួលបានព័ត៌មានពីគ្រប់ទម្រង់ (Richter et al. 2023)។ ស្របពេលដែលសេចក្តីព្រាងច្បាប់ ស្តីពីសិទ្ធិទទួលបានព័ត៌មាន បានរំលេចខ្លឹមសារទាក់ទងនឹងជនមានពិការភាព ដែលជាការឆ្លុះបញ្ចាំងនូវជំហានវិជ្ជមានមួយ ភាពសកម្មនៃគំនិតផ្តួចផ្តើម កិច្ចខិតខំប្រឹងប្រែងក្នុងការតស៊ូមតិ និងការប្តេជ្ញាចិត្តក្នុងការអនុវត្តប្រកបដោយចីរភាព ពិតជាមានសារៈសំខាន់ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលកើតមាន។

សង្ខេបគោលនយោបាយនេះបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវមួយទាក់ទងនឹង "ការវាយតម្លៃតម្រូវការព័ត៌មាន សម្រាប់ជនមានពិការភាពនៅកម្ពុជា" ដែលធ្វើឡើងដោយ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) សហការ ជាមួយការិយាល័យយូណេស្កូភ្នំពេញ (UNESCO) ក្រោមការគាំទ្រផ្នែកហិរញ្ញវត្ថុពីដៃគូរបស់អង្គការ សហប្រជាជាតិ ដើម្បីលើក

រៀបរៀងដោយ ប៊ុន ភូរី អ្នកស្រាវជ្រាវ និង ជា ផល អ្នកស្រាវជ្រាវជាន់ខ្ពស់ មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ នៃវិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា៖ Bun Phoury and Chea Phal. 2024. *Closing the Information Divide: Addressing the Information Needs for Persons with Disabilities in Cambodia.* Policy Brief 2024 No. 01. Phnom Penh: CDRI.

១ សម្ភារៈព័ត៌មាន អប់រំ និងទំនាក់ទំនង [Information, Education, Communication Materials (IEC)]

កម្ពស់ សិទ្ធិជនមានពិការភាព និងមូលនិធិពហុដៃគូសម្រាប់ពិការភាព។ ការសិក្សានេះបានបង្ហាញពី គម្លាតក្នុងការទទួលបានព័ត៌មានរបស់ជនមានពិការភាពនៅប្រទេសកម្ពុជា និងផ្តល់នូវអនុសាសន៍ផ្អែកលើភស្តុតាងស្រាវជ្រាវ ដើម្បីបង្កើនលទ្ធភាពទទួលបានព័ត៌មានរបស់ពួកគេ។ ការស្រាវជ្រាវនេះបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបចម្រុះ ដោយរួមបញ្ចូលការវិភាគទិន្នន័យពីស្ថិតិសុខភាពប្រជាសាស្ត្រកម្ពុជា(CDHS)ឆ្នាំ២០២១-២២រឺវេចនាទិន្នន័យ និងទិន្នន័យពីការសម្ភាស ព្រមទាំងការពិភាក្សាក្រុម។

## លទ្ធផលស្រាវជ្រាវ

### *ប្រជាសាស្ត្រ*

នៅប្រទេសកម្ពុជា ប្រជាជនប្រមាណ ២៤% ដែលមានអាយុលើសពី ៥ឆ្នាំ បានជួបប្រទះនឹងបញ្ហាពិការភាព។ អត្រាប្រេវ៉ាឡង់ពិការភាពនេះ កើតមានខ្ពស់ចំពោះស្ត្រី មនុស្សចាស់ និងអ្នកដែលរស់នៅទីជនបទ។ អត្តសញ្ញាណពិការភាព ដែលបានរាយការណ៍ភាគច្រើនរួមមាន ការលំបាកក្នុងការមើលឃើញ ការចងចាំ និងការដើរឬការធ្វើចលនាបម្លាស់ទីជាដើម។ ជនមានពិការភាពទទួលបានការអប់រំក្នុងកម្រិតទាប ដោយមានតែ ២៥% ប៉ុណ្ណោះដែលបានបញ្ចប់ថ្នាក់បឋមសិក្សា និងត្រឹមតែ ៦% ប៉ុណ្ណោះដែលឈានដល់កម្រិតមធ្យមសិក្សា ឬខ្ពស់ជាងនេះ។ ជនមានពិការភាពភាគច្រើន ធ្វើការងារដែលមិនទទួលបានប្រាក់កម្រៃ។ បញ្ហាវិសមភាពយេនឌ័រ បានកើតមានក្នុងបរិបទការងារដែលយើងឃើញថា អត្រាបុរសដែលទទួលបានការងារ គឺច្រើនជាងស្ត្រី ប៉ុន្តែជនមានពិការភាពធ្ងន់ធ្ងរទាំងពីរភេទ ជារួមមានឱកាសតិចតួចក្នុងការចូលរួមផ្នែកពលកម្ម និងទទួលបានការងារដែលបានប្រាក់កម្រៃ។ លើសពីនេះ ជនមានពិការភាពប្រឈមមុខខ្លាំងជាមួយនឹងបញ្ហាសុខភាព និងការទទួលបានសេវាសាធារណៈចាំបាច់នៅមានកម្រិត ដូចជាទឹកស្អាត និងអនាម័យជាដើម។ ក្រុមជនមានពិការភាព ក៏មានបញ្ហាសុខភាពច្រើនជាងបុគ្គលដែលគ្មានពិការភាពប្រមាណ ១៥%។

## ស្ថានភាពគោលនយោបាយ និងការអនុវត្ត

រហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាមិនទាន់មានក្របខណ្ឌច្បាប់ជាក់លាក់ណាមួយ ក្នុងការដោះស្រាយលទ្ធភាពទទួលបានព័ត៌មាន ជាពិសេសសម្រាប់ជនមានពិការភាព ដែលធ្វើឱ្យការអនុវត្ត មានភាពលំបាក។ ខណៈពេលដែលការផ្សព្វផ្សាយព័ត៌មានកំពុងរីកចម្រើន យើងឃើញថា លទ្ធភាពទទួលបានព័ត៌មានសម្រាប់បុគ្គលគ្រប់រូប ភាពទាន់ពេលវេលា និងមិនមាន

រូបភាពទី១៖ ការប្រៀបធៀបរវាងស្ថានភាពគោលនយោបាយ និងការអនុវត្ត ទាក់ទងនឹងការទទួលបានព័ត៌មានសម្រាប់ជនមានពិការភាព



ការគិតប្រាក់កម្រៃ មិនទាន់បានជាផ្លែផ្កាច្រើននៅឡើយ។ លើសពីនេះ អន្តរកម្មផ្លូវច្បាប់ ឬផ្លូវការទាំងឡាយ គួរមានការទទួលយកបន្ថែមនូវការសម្របសម្រួល ដោយប្រើមធ្យោបាយទំនាក់ទំនងនានា ឬការប្រើប្រាស់បច្ចេកវិទ្យាជាជំនួយ សម្រាប់ប្រភេទពិការភាពផ្សេងៗក្នុងអន្តរកម្មនោះ។ គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលក្នុងការជំរុញឱ្យស្ថាប័នឯកជន ផ្តោតលើលទ្ធភាពទទួលបានព័ត៌មានសម្រាប់បុគ្គលគ្រប់រូប រួមទាំងជនមានពិការភាព ក៏នៅអសកម្មនៅឡើយ។ ដូចគ្នានេះដែរ កិច្ចសហការជាមួយដៃគូបណ្តាញផ្សព្វផ្សាយ ដើម្បីបង្កើនលទ្ធភាពទទួលបានមាតិកាព័ត៌មានកន្លងមក ទទួលបានលទ្ធផលតិចតួចបំផុត។ លើសពីនេះភាពមានកម្រិតនៃធនធាន បានរារាំងកិច្ចការងារដើម្បីលើកកម្ពស់ចំណេះដឹងការយល់ដឹងទូលំទូលាយពីបរិយាបន្នពិការភាព និងលទ្ធភាពទទួលបានព័ត៌មានផងដែរ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល នៅតែបន្តសហការគ្នាលើបញ្ហានេះ។ គំនិតផ្តួចផ្តើម ដូចជាការអភិវឌ្ឍស្តង់ដាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ គឺជាជំហានវិជ្ជមានមួយ។ សូមមើលរូបភាពទី១ សម្រាប់ការប្រៀបធៀបខ្លីៗរវាងគោលនយោបាយ និងការអនុវត្ត។

## ស្ថានភាពនៃការទទួលបានព័ត៌មាន

### *មធ្យោបាយទំនាក់ទំនង/ផ្លាស់ប្តូរព័ត៌មាន*

ជនមានពិការភាព បានប្រើប្រាស់មធ្យោបាយចម្បងចំនួនបួន ដើម្បីទទួលបានព័ត៌មានផ្សេងៗ ក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ មធ្យោបាយទាំងនោះ រួមមាន ប្រព័ន្ធផ្សព្វផ្សាយ (តាមរយៈឧបករណ៍ផ្សព្វផ្សាយ និងបណ្តាញសង្គម) ភ្នាក់ងារ ព្រឹត្តិការណ៍ និងសម្ភារៈ IEC (សូមមើលរូបភាពទី២)។

ខណៈពេលដែលមធ្យោបាយទាំងនេះ ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ យើងឃើញថាវាមិនទាន់អាចបំពេញតម្រូវការរបស់ជនមានពិការភាព ឱ្យសមស្របទៅតាមប្រភេទនៃពិការភាពនៅឡើយទេ។ យើងក៏សង្កេតឃើញមានបញ្ហាមិនបន្សុីគ្នា រវាងមធ្យោបាយដែលប្រើប្រាស់ដោយជនមានពិការភាព សម្រាប់ទទួលបានព័ត៌មាន និងទម្រង់ព័ត៌មាន ដែលប្រើដោយអ្នកផ្តល់ព័ត៌មាន។ ឧទាហរណ៍ ជារឿយៗ ដៃគូអភិវឌ្ឍន៍បានផ្តោតលើការធ្វើទំនាក់ទំនងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ជាជាងការប្រាស្រ័យទាក់ទងដោយផ្ទាល់ ជាមួយជនមានពិការភាព ដោយប្រើមធ្យោបាយទំនាក់ទំនងផ្សេងៗ។

រូបភាពទី២៖ មធ្យោបាយទំនាក់ទំនង ដើម្បីទទួលបានព័ត៌មាន សម្រាប់ជនមានពិការភាព



### *ព័ត៌មានដែលអាចប្រើប្រាស់/ទទួលបាន នាពេលបច្ចុប្បន្ន*

បច្ចុប្បន្ន ជនមានពិការភាពអាចទទួលបានព័ត៌មានចំនួនប្រាំប្រភេទធំៗគឺ៖ ព័ត៌មានសេដ្ឋកិច្ច ការអប់រំ ការថែទាំសុខភាព នយោបាយ និងព័ត៌មានសង្គម និងវប្បធម៌។ ព័ត៌មានសង្គមនិងវប្បធម៌ ជាប្រភេទព័ត៌មានដែលពួកគេអាចទទួលបានក្នុងអត្រាខ្ពស់បំផុត ហើយអត្រានេះបានថយចុះជាបន្តបន្ទាប់សម្រាប់លទ្ធភាពទទួលបានព័ត៌មានផ្នែកសេដ្ឋកិច្ច ការថែទាំសុខភាព នយោបាយ និងការអប់រំ។ កង្វះលទ្ធភាពទទួលបានព័ត៌មាន ច្រើនកើតមានចំពោះស្ត្រីដែលមានពិការភាពច្រើនប្រភេទ បុគ្គលមានវ័យចំណាស់ បុគ្គលក្រីក្រ ដែលមានការអប់រំទាប រស់នៅជនបទ និងជាក្រុមជនជាតិដើមភាគតិច។ យើងក៏សង្កេតឃើញភាពមិនបន្សុីគ្នា រវាងព័ត៌មានដែលផ្តល់ដោយរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងអង្គការតំណាងជនមានពិការភាព ជាមួយនឹងប្រភេទព័ត៌មានដែលទទួលបានដោយជនមានពិការភាព។ រាជរដ្ឋាភិបាលកម្ពុជាហាក់ដូចជាផ្តល់ព័ត៌មានបែបទូលាយ ចំណែកឯអង្គការក្រៅរដ្ឋាភិបាល និងអង្គការតំណាងជនមានពិការភាព ភាគច្រើនផ្តោតលើការតស៊ូមតិការពារសិទ្ធិ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងព័ត៌មានថែទាំសុខភាព។ ភាពមិនបន្សុីគ្នានេះ បង្ហាញពីតម្រូវការកំណែទម្រង់បន្ថែម និងបង្កើនលទ្ធភាពទទួលបានព័ត៌មាន ដើម្បីបំពេញតម្រូវការផ្សេងៗរបស់ជនមានពិការភាព។

## បញ្ហាប្រឈមក្នុងការទទួលបានព័ត៌មាន

### *កត្តាខាងក្រៅ*

កត្តាខាងក្រៅត្រូវបានសម្គាល់ជាឧបសគ្គដ៏ធំបំផុត។ កត្តាទាំងនោះរួមមាន ភាពមានកម្រិតនៃវត្តមានបច្ចេកវិទ្យាដែលអាចប្រើប្រាស់បានដូចជា កម្មវិធីអានលើអេក្រង់ ការបង្ហាញអក្សរប្រៃល (Braille)[២] និងការបកស្រាយជាភាសាសញ្ញា។ ជារឿយៗបច្ចេកវិទ្យាជំនួយ ដែលមានស្រាប់ មិនអាចឆ្លើយតបទៅនឹងបរិបទក្នុងស្រុក ដោយសាររបាំងភាសា ព្រោះបច្ចេកវិទ្យាទាំងនោះមិនមានជាភាសាខ្មែរ។ កម្រិតអក្ខរកម្មឌីជីថលក្នុងចំណោមជនមានពិការភាព ក៏នៅមានកម្រិតទាប ដែលបានប៉ះពាល់ដល់សមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាទាំងនោះផងដែរ។ គម្លាតឌីជីថលក៏ចោទជាបញ្ហាខ្លាំងដែរ ដោយសារ ដែនប្រព័ន្ធអ៊ីនធឺណិតនៅប្រទេសកម្ពុជាមានប្រហែល ៦៧,៥% ប៉ុណ្ណោះ ហើយភាគច្រើនមាននៅតំបន់ទីប្រជុំជន។ ស្ថានភាពមិនអំណោយផលនៃបរិស្ថានធម្មជាតិ និងសំណង់រួមទាំងភាពខ្វះចន្លោះនៃមធ្យោបាយសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ ធ្វើឱ្យបញ្ហាប្រឈមទាំងនេះកាន់តែធ្ងន់ធ្ងរ។ ការរើសអើង និងកង្វះការគាំទ្រពីគ្រួសារ និងសហគមន៍ ក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់លទ្ធភាពទទួលបានព័ត៌មានរបស់ជនមានពិការភាពដែរ។ ជារឿយៗគ្រួសារផ្តល់អាទិភាពដល់ការស្វែងរកប្រាក់ចំណូល ជាជាងជួយបំពេញតម្រូវការព័ត៌មានរបស់ជនមានពិការភាព ស្របពេលដែលការយល់ដឹងពីរបៀបជួយជនមានពិការភាពឱ្យមានប្រសិទ្ធភាព ក៏មានភាពខ្វះខាតផងដែរ។

### *លក្ខខណ្ឌសុខភាព*

លក្ខខណ្ឌសុខភាព ក៏ជារបាំងរាំងចំបងដល់ការទទួលបានព័ត៌មានផងដែរ។ ប្រភេទចំនួន និងភាពធ្ងន់ធ្ងរនៃពិការភាព រួមជាមួយនឹងស្ថានភាពសុខភាពរ៉ាំរ៉ៃ អាចរាំងលទ្ធភាពទទួលបាន និងប្រើប្រាស់ព័ត៌មាន។ ឧទាហរណ៍ អ្នកពិការភ្នែកអាចពិបាកអានឯកសារដែលបានបោះពុម្ព ឬការប្រើប្រាស់គេហទំព័រឌីជីថល ហើយអ្នកដែលមានបញ្ហាក្នុងការស្តាប់ អាចជួបការលំបាកជាមួយព័ត៌មានដែលផ្សាយជាសំឡេង។ ភាពចាស់ជរា និងពិការភាពធ្ងន់ធ្ងរ បានពង្រីកបញ្ហាប្រឈមទាំងនេះ ដែលធ្វើឱ្យជនមានពិការភាព ពិបាកក្នុងការទទួលបាន និងប្រើប្រាស់ព័ត៌មានប្រកបដោយប្រសិទ្ធភាព។

### *កត្តាខាងក្នុង*

កត្តាខាងក្នុងរួមមាន កង្វះការលើកទឹកចិត្ត និងទំនុកចិត្តលើខ្លួនឯងដែលជាកត្តារាំងជនមានពិការភាពមិនឱ្យទទួលបានព័ត៌មាន។ ជនមានពិការភាពជាច្រើន ធ្លាប់មានបទពិសោធន៍បរាជ័យពីអតីតកាល ឬលំបាកក្នុងការយល់ដឹងអំពីព័ត៌មាន ដែលបំបាក់ទឹកចិត្តមិនឱ្យពួកគេព្យាយាមបន្តស្វែងរក និងស្វែងយល់ព័ត៌មានបន្ថែម។ ភាពឯកោ ការរើសអើង និងការបន្ទាបតម្លៃខ្លួនឯង ក៏ធ្វើឱ្យជនមានពិការភាព មានការស្ទាក់ស្ទើរក្នុងការចូលរួមទទួលព័ត៌មាន។ លើសពីនេះទៀត កង្វះការយល់ដឹងអំពីភាពពាក់ព័ន្ធ និងសារៈសំខាន់នៃព័ត៌មានសម្រាប់ជីវិត បានកាត់បន្ថយទឹកចិត្តរបស់ជនមានពិការភាព ក្នុងការស្វែងរក និងប្រើប្រាស់ព័ត៌មាន។ របាំងផ្នែកខាងក្នុងនេះ បង្កើតជាវដ្តនៃការមើលរំលងជនមានពិការភាព ជាពិសេសនៅពេលដែលបន្តមានកង្វះការលើកទឹកចិត្ត ដែលនាំឱ្យកាត់បន្ថយការចូលរួមរបស់ជនមានពិការភាពក្នុងសង្គម។

### *តើជនមានពិការភាពត្រូវការព័ត៌មានអ្វីខ្លះ?*

ការសិក្សានេះ បានរកឃើញប្រភេទព័ត៌មានសំខាន់ៗចំនួនប្រាំពីរ ដែលមានតម្រូវការខ្ពស់ រួមមាន៖ ព័ត៌មានសេដ្ឋកិច្ច ការអប់រំ និងបណ្តុះបណ្តាល សេវាសុខភាព សេវាសាធារណៈ

[២] ជាប្រភេទអក្សរស្ទាបសម្រាប់អ្នកដែលមានពិការភាពផ្នែកគំហើញ។

ព័ត៌មានសង្គម និងវប្បធម៌ ព័ត៌មានទាក់ទងនឹងពិការភាព និងព័ត៌មានបរិស្ថាន (សូមមើលរូបភាពទី៣)។ ដើម្បីកែលម្អលទ្ធភាពទទួលបាន និងលទ្ធភាពប្រើប្រាស់ព័ត៌មានសម្រាប់ជនមានពិការភាព ព័ត៌មានក៏គួរតែមានលក្ខណៈដូចខាងក្រោម៖

- **ទម្រង់ដែលមានលក្ខណៈសម្រឹតសម្រាំង៖** ព័ត៌មានគួរតែផលិត និងមានច្រើនទម្រង់ ដូចជាការប្រើអក្សរប្រ៊ែល សំឡេង ការបោះពុម្ពអក្សរធំៗ ការបកស្រាយជាភាសាសញ្ញា និងការដាក់ចំណងជើង។
- **គួរឱ្យទុកចិត្ត និងមានប្រភពច្បាស់លាស់៖** ព័ត៌មានត្រូវតែមកពីប្រភពដែលអាចទុកចិត្តបាន ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងទំនុកចិត្ត។
- **បានបកប្រែ៖** ព័ត៌មានគួរតែត្រូវបានបកប្រែជាភាសាខ្មែរ និងភាសាពាក់ព័ន្ធផ្សេងទៀតផងដែរ ដើម្បីធានាបាននូវបរិយាបន្ន ជាពិសេសសម្រាប់ក្រុមជនជាតិដើមភាគតិច។
- **ច្បាស់លាស់ និងសាមញ្ញ៖** ព័ត៌មានគួរតែត្រូវបានបង្ហាញជាភាសាសាមញ្ញ ជៀសវាងការប្រើពាក្យបច្ចេកទេសច្រើន និងគួរតែរៀបចំក្នុងទម្រង់ដែលងាយស្រួលមើល និងទទួលបាន។
- **ទាន់ពេលវេលា៖** ព័ត៌មានថ្មីៗ ជាពិសេសផ្នែកសុខភាព ហិរញ្ញវត្ថុ និងឱកាសការងារ ពិតជាមានប្រយោជន៍ណាស់ ប្រសិនបើអាចផ្តល់ឱ្យទាន់ពេលវេលា។
- **ដាក់ក្នុងវេទិកាដែលងាយស្រួលទទួលបាន៖** ព័ត៌មានគួរតែដាក់ក្នុងវេទិកាដែលងាយស្រួលទទួលបានដើម្បីធានាថាជនមានពិការភាពអាចទទួលបានព័ត៌មានថ្មីៗភ្លាមៗ និងមានប្រសិទ្ធភាព។

រូបភាពទី៣៖ ប្រភេទ និងលក្ខណៈនៃព័ត៌មានដែលជនមានពិការភាពត្រូវការ



**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ +៨៥៥២៣ ៨៨១-៧០១ cdri@cdri.org.kh; www.cdri.org.kh

## អនុសាសន៍

- **កំណែទម្រង់ច្បាប់ និងគោលនយោបាយ៖** ដើម្បីដោះស្រាយគម្លាត និងបញ្ហាប្រឈមដែលកើតមានកំណែទម្រង់ច្បាប់ និងគោលនយោបាយ មានសារៈសំខាន់ណាស់។ ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន គួរតែត្រូវបានពន្លឿន និងអនុម័តជាមួយនឹងបទប្បញ្ញត្តិជាក់លាក់ដែលអាចបំពេញតម្រូវការរបស់ជនមានពិការភាព។ លើសពីនេះ គោលនយោបាយជាតិដែលមានស្រាប់គួរអនុវត្តឱ្យបន្សុីគ្នាស្របតាមគោលការណ៍នៃមាត្រា ៩ និង២១ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិជនមានពិការភាព ដើម្បីធានាបាននូវលទ្ធភាពទទួលបានព័ត៌មានដ៏ទូលំទូលាយ។
- **ការកសាងសមត្ថភាព និងការយល់ដឹង៖** ការផ្តួចផ្តើមរៀបចំកសាងសមត្ថភាពគឺមានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់ការយល់ដឹង និងការអនុវត្តបរិយាបន្នពិការភាព ព្រមទាំងលទ្ធភាពទទួលបានព័ត៌មានពីមន្ត្រីរដ្ឋាភិបាល អ្នកផ្តល់ព័ត៌មាន និងសាធារណជនទូទៅ ។ ការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់ជនមានពិការភាព ក្នុងការទទួលបានព័ត៌មាន អាចរួមចំណែកយ៉ាងសំខាន់ដល់កិច្ចខិតខំប្រឹងប្រែងនេះ។
- **ការតាមដាន និងការត្រួតពិនិត្យ៖** ការបង្កើតស្ថាប័នជំនាញដើម្បីត្រួតពិនិត្យតាមដានអនុវត្តនិងរាយការណ៍អំពីស្ថានភាពនៃលទ្ធភាពទទួលបានព័ត៌មានគឺចាំបាច់។ ស្ថាប័ននេះ គួរតែមានធនធានគ្រប់គ្រាន់ និងមានរចនាសម្ព័ន្ធសមស្របក្នុងការអភិវឌ្ឍ និងអនុវត្តគោលការណ៍ណែនាំជាតិស្តីពីលទ្ធភាពទទួលបានព័ត៌មាននៅគ្រប់វិស័យ។
- **ការបង្កើនគុណភាពហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា៖** ការវិនិយោគលើបច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធដែលងាយស្រួលប្រើប្រាស់គឺមានសារៈសំខាន់សម្រាប់គាំទ្រដល់ការទទួលបានព័ត៌មានសម្រាប់ជនមានពិការភាព។ ការធានាថារាល់វេទិកាទំនាក់ទំនងជាសាធារណៈ និងសេវាកម្មទាំងអស់ ត្រូវបានរចនាឡើង សម្រាប់ឱ្យជនដែលមានពិការភាពគ្រប់ប្រភេទ អាចប្រើប្រាស់បាន។ កត្តានេះនឹងជួយពង្រឹងសមត្ថភាពជនមានពិការភាពក្នុងការទទួលបានព័ត៌មានសំខាន់ៗ។
- **ការចូលរួមជាមួយវិស័យឯកជន និងប្រព័ន្ធផ្សព្វផ្សាយ៖** ការចូលរួមជាមួយស្ថាប័នឯកជន និងដៃគូផ្សព្វផ្សាយសាធារណៈ គឺជាជំហានសំខាន់មួយទៀត។ ស្ថាប័នឯកជនគួរតែត្រូវបានលើកទឹកចិត្តឱ្យផ្តល់ព័ត៌មានក្នុងទម្រង់ដែលងាយស្រួលប្រើប្រាស់ និងផ្សព្វផ្សាយដោយប្រើភាសាសញ្ញា ជាមួយមធ្យោបាយទំនាក់ទំនងបន្ថែមផ្សេងទៀត។ ភាពជាដៃគូរវាងរដ្ឋាភិបាល វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល អាចជួយសម្រួលដល់គំនិតផ្តួចផ្តើមនានា ដើម្បីកែលម្អលទ្ធភាពទទួលបានព័ត៌មាន។

## ឯកសារយោង


Madaus, Joseph W., Nicholas Gelbar, Michael Faggella-Luby and Lyman L. Dukes III. 2021. "Experiences of Students with Disabilities during the COVID-19 Interruption of In-Person Instruction." *Journal of Postsecondary Education and Disability* 34 (1) 5-18.

Mitra, Sophie, and Michael Palmer. 2023. "Economic of Disability". *In K.F. Zimmermann (Ed.), Handbook of Labor, Human Resources and Population Economics.* New York: Springer.

Richter, Andrey, Lida Ayoubi, Jaco Du Toit, Marius Lukosiunas and Ingrid Mondet. 2023. *A Steady Path Forward: UNESCO 2022 Report on Public Access to Information* (SDG 16.10.2). Paris: UNESCO

United Nations. 2006. *Convention on the Rights of Persons with Disabilities – Articles.* UN Department of Economic and Social Affairs. https://www.un.org/development/desa/disabilities/convention-on-the-rights-of-persons-with-disabilities/convention-on-the-rights-of-persons-with-disabilities-2.html.